# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jul-2013, 08:43
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្រ្តីកត់ត្រា:

ហត្ថលេខា:

---

## ការដកសេចក្តីជូនដំណឹងពីបំណងអនុលោមតាមវិធាន៩០

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

សួន វិសាល

Joshua ROSESWEIG
Forest O'NEILL-GREENBERG
Elizabeth BUDNITZ

Tamara BURUMA

**<u>ផ្ញើជូន៖</u>**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

សហមេធាវីការពារក្ដីជនជាប់ចោទ នួន ជា (“ក្រុមមេធាវីការពារក្ដី”) តទៅនេះសូមដាក់ការជូនដំណឹងជាផ្លូវការរបស់ នួន ជា អំពីការដកបំណងរបស់គាត់ ដើម្បីឆ្លើយតបទៅនឹងសំណួរនានា អនុលោមតាមវិធាន៩០៖

១. នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងតាមរយៈការណែនាំដោយផ្ទាល់មាត់ បានស្នើជនជាប់ចោទនិមួយៗឲ្យផ្ដល់ការជូនដំណឹងថា តើពួកគេមានបំណងឆ្លើយតបទៅនឹងសំណួរអនុលោមតាមវិធាន៩០ ឬជាជម្រើសមកវិញ ប្រើប្រាស់សិទ្ធិរបស់ពួកគេនៅស្ងៀមមិនឆ្លើយនឹងសំណួរដែរ ឬយ៉ាងណា។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ក្រុមមេធាវីការពារបានជូនដំណឹងដល់អង្គជំនុំជម្រះថា នួន ជា នឹងឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងបញ្ហានានាដែលកំណត់នៅក្រុងវិសាលភាពយុត្តាធិការពេលវេលា[1]។

២. ក្នុងអំឡុងពេលសប្ដាហ៍ថ្ងៃទី៨ និងសប្ដាហ៍ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ សាក្សី Stephen Heder បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះដើម្បីស្ដាប់សក្ខីកម្ម។ ក្នុងអំឡុងពេលការដាក់សំណួរដោយក្រុមមេធាវីការពារក្ដីមកលើលោក Heder ការជំទាស់ដដែលៗប្រឆាំងនឹងសំណួរសាមញ្ញទាក់ទងនឹងអង្គហេតុយ៉ាងច្បាស់ដែលឋិតក្នុងកម្រិតព្រំដែនត្រឹមត្រូវ នៃការសាកសួរសាក្សី ត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី និងគាំទ្រដោយអង្គជំនុំជម្រះនេះ ។ ការជំទាស់នេះធ្វើឡើងជាប្រព័ន្ធដោយមិនសមហេតុផល និងមានចេតនាមិនធានាដល់ការអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះ ប៉ុន្តែដើម្បីបង្អាក់ និងធ្វើឲ្យអន្តរាយដល់ការសួរដេញដោលរបស់ នួន ជា ចំពោះលោក Heder។ ការគាំទ្រដល់ការជំទាស់ទាំងនេះអង្គជំនុំជម្រះមិនត្រឹមតែដាក់កម្រិតយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់មេធាវីការពារក្ដីដើម្បីតទល់សាក្សីទេ តែថែមទាំងបានអនុវត្តបទដ្ឋានផ្សេងៗគ្នាចំពោះសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី។ មេធាវីការពារក្ដីត្រូវបានអនុញ្ញាតឲ្យសួរតិចជាងពាក់កណ្ដាលនៃសំណួរដែលខ្លួនបានរៀបចំសម្រាប់ការសួរដេញដោយលលោក Heder។ ការសួរដេញដោលដល់សាក្សីដែល

[1] ឯកសារ E-287 “ការជូនដំណឹងនៃបំណងអនុលោមតាមវិធាន៩០ នៃវិធានផ្ទៃក្នុង” ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ។

អនុញ្ញាតដល់មេធាវីការពារក្តី មិនបានគោរពតាមទម្រង់ណាមួយនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់ភស្តុតាងប្រឆាំងនឹងគាត់។

៣. នួន ជា ព្រមទាំងក្រុមមេធាវីការពារក្តីទាំងមូលរបស់គាត់ មានកំហឹងយ៉ាងខ្លាំងបង្កឡើងដោយព្រឹត្តិការណ៍ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ ។ ការយល់ស្របគ្នាមួយកើតមានភ្លាមៗថា នួន ជា នឹងមិនសហការជាមួយអង្គជំនុំជម្រះនេះ ដែលបង្ហាញយ៉ាងជាក់ច្បាស់ពីការមិនយកចិត្តទុកដាក់នៅក្នុងការស្វែងរកអង្គហេតុដ៏សំខាន់នេះ។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ នួន ជា បានធ្វើការសម្រេចចុងក្រោយ ដើម្បីដកការជូនដំណឹងរបស់គាត់អំពីបំណងឆ្លើយតបទៅនឹងសំណួរ គាត់បានបង្ហាញការសម្រេចនេះនៅចំពោះមុខអង្គជំនុំជម្រះនៅរសៀលថ្ងៃនោះ[2]។

៤. គោលបំណងនៃការដកការជូនដំណឹងនេះ គឺដើម្បីប្រកាសជាផ្លូវការលើការចង្អុលបង្ហាញលើកមុនដោយ នួន ជា កាលពីថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៣ និងដើម្បីបញ្ជាក់នូវមូលហេតុចំពោះការសម្រេចនោះ ។ វាមិនមែនជាការសម្រេចដែល នួន ជា ធ្វើឡើងដោយលឿនៗនោះទេ ហើយក៏មិនមែនជាវិធីដែលគាត់ចង់បញ្ចប់ការជំនុំជម្រះនេះដោយរបៀបនេះដែរ ។ តែវាគឺជាការសម្រេចដែលគាត់ធ្វើដោយបង្ខំ បន្ទាប់ពីបានពិភាក្សាជាមួយមេធាវីការពារក្តី ។

## I. **សក្ខីកម្មរបស់ Stephen Heder**

៥. យ៉ាងហោចណាស់មានរបៀបបីដែរ ដែលការជំទាស់ដែលត្រូវបានគាំទ្រដោយអង្គជំនុំជម្រះប្រឆាំងនឹងការដាក់សំណួរដោយក្រុមមេធាវីការពារក្តីមកលើលោក Heder គឺមិនសមស្របនឹងសិទ្ធិរបស់ នួន ជា ក្នុងការតទល់ភស្តុតាងប្រឆាំងនឹងគាត់ និងការណែនាំរបស់របស់អង្គជំនុំជម្រះទាក់ទងនឹងការសួរដេញដោលសាក្សី គឺយ៉ាងហោចណាស់តាមវិធីបីផ្សេងគ្នា។

៦. ទីមួយ អង្គជំនុំជម្រះនេះដាក់កម្រិតដោយបំពានលើទម្រង់នៃការដាក់សំណួរដោយមេធាវីការពារក្តីតាមរយៈការគាំទ្រដល់ការជំទាស់ដដែលៗ ប្រឆាំងនឹងសំណួរនៃអង្គហេតុដោយសារតែសំណួរទាំងនេះមិនត្រូវបានលើកឡើងតាមវិធីសាស្ត្រនៃការអានឲ្យសាក្សីស្តាប់ នូវសម្រង់មួយពីស្នាដៃរបស់គាត់ ហើយជាបន្ទាប់ស្នើសុំមូលដ្ឋានអង្គហេតុដែលគាំទ្រដល់ការអះអាងនោះ ។ ការលើកឡើងរបស់អង្គជំនុំជម្រះអំពីដែនកំណត់សម្រាប់ការសួរដេញដោលសាក្សី មាននៅ

---

[2] ឯកសារ E-1/225.1 "ប្រតិចារិតសវនាការ" ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ នៅទំព័រ 67:9-68: 5។

ក្នុងសារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ មិនបានបញ្ចូលនូវការកដាក់កម្រិតបែបនេះទេ ។ សារអេឡិចត្រូនិកនេះចង្អុលបង្ហាញថា "សំណួរត្រូវតែទាក់ទងជាបឋមជាមួយភស្តុតាងដែលសាក្សីប្រមូលបានក្នុងពេលធ្វើការសម្ភាសន៍ដែលគាត់បានធ្វើនៅមុន ឬក្នុងអំឡុងពេលគាត់ធ្វើនៅ អវតក ឬភស្តុតាងដែលគាត់ប្រមូលបានក្នុងពេលស្រាវជ្រាវដែលបង្កើតជាមូលដ្ឋានសម្រាប់សៀវភៅ ឬអត្ថបទនានានិពន្ធដោយរូបគាត់ (បញ្ជាក់បន្ថែម)[3]។ ការពិនិត្យមើលការណែនាំនោះភ្ជាប់នឹងលិខិត មេធាវីការពារក្តីបានសួរលោក Heder អំពីអង្គហេតុដែលគាត់រកឃើញក្នុងអំឡុងពេលការសម្ភាសន៍របស់គាត់។ ឧទាហរណ៍ "តើលោកមានព័ត៌មានអង្គហេតុពីការសម្ភាសន៍របស់លោក ឬការសិក្សារបស់លោកលើឯកសារជាច្រើនអំពីតួនាទីរបស់កងទ័ពភូមិភាគបូព៌ាក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ ឬទេ?[4]

៧. ផ្ទុយទាំងស្រុងពីការណែនាំរបស់អង្គជំនុំជម្រះនេះ សហព្រះរាជអាជ្ញាបានជំទាស់ថាសំណួរនេះមិនអាចអនុញ្ញាតបានឡើយ ពីព្រោះសំណួរជាច្រើនដែលតាំងចំពោះលោក Heder ត្រូវតែយោងទៅលើសៀវភៅមួយ ឬសម្រង់ពីសៀវភៅមួយដែលនិពន្ធដោយលោក Heder[5]។ តាមពិតពុំមានផ្នែកណាមួយនៃអនុស្សរណៈរបស់អង្គជំនុំជម្រះ តម្រូវឱ្យភាគីតាំងសំណួរដោយការយោងទៅលើសម្រង់នៅក្នុងអត្ថបទដែលនិពន្ធដោយសាក្សីនោះទេ ។ តាមពិតអនុស្សរណៈនិយាយផ្ទុយពីនេះយ៉ាងពិតប្រាកដៈ សំណួរអាចពាក់ព័ន្ធភស្តុតាងដែលប្រមូលដោយសាក្សីនេះ ឬប្រើប្រាស់ដោយសាក្សីធ្វើជាមូលដ្ឋានសម្រាប់ស្នាដៃនិពន្ធរបស់គាត់ ។ ការណែនាំណាមួយដទៃទៀតនឹងមិនសមហេតុផលឡើយ ដោយសារវានឹងមិនអនុញ្ញាតចំពោះការស្វែងរកព័ត៌មានអង្គហេតុណាមួយ ដែលសាក្សីមិនបានសរសេរសូម្បីតែមួយប្រយោគនៅក្នុងអត្ថបទមួយ។ តាមពិតការសម្រេចបែបនេះមានអនុភាពផ្ទុយយ៉ាងពិតប្រាកដនៃការប្រព្រឹត្តលើលោក Heder ជាសាក្សីជាគ្រូហស្ថៈ តម្រូវឱ្យភាគីផ្តោតទៅលើតែមូលដ្ឋានសម្រាប់ការសន្និដ្ឋាននានាដែល

---

[3] សារអេឡិចត្រូនិកពី Ken Roberts ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ។

[4] ឯកសារ E-1/224.1 "ប្រតិចារិតសវនាការ" ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ (ប្រតិចារិតថ្ងៃទី១៦ ខែកក្កដា) នៅទំព័រ 87: 3-5 ។

[5] ប្រតិចារិតថ្ងៃទី១៦ ខែកក្កដា នៅទំព័រ 87: 10-89:10

គាត់បានធ្វើ ក្នុងខណៈជាអ្នកជំនាញ ជាជាងអង្គហេតុដែលគាត់អាចជាបានដឹងក្នុងរបៀបផ្សេងទៀត ។ ការដែលសហព្រះរាជអាជ្ញាប្រព្រឹត្តទៅក្នុងលក្ខណៈបែបនេះក្នុងអំឡុងពេលពួកគេសួរដេញដោលសាក្សី គឺមិនពាក់ព័ន្ធទាំងស្រុងចំពោះទម្រង់នៃការតាំងសំណួរ ដែលតម្រូវពីភាគីដទៃ។

៨. តាមពិតថ្មីបើនៅ ពេលមេធាវីការពារក្ដីបន្តដោយការដាក់ប្រធានបទមកសាក្សីចេញពីស្នាដៃរបស់គាត់ ក៏សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីនៅតែជំទាស់ដដែល ហើយការជំទាស់ទាំងនោះជាថ្មីម្ដងទៀតត្រូវបានគាំទ្រដោយអង្គជំនុំជម្រះ[6]។ មូលដ្ឋានសម្រាប់ការជំទាស់នេះ គឺថាពុំមានជើងអក្សរភ្ជាប់ជាមួយសម្រង់ដែលបានអានឲ្យសាក្សីស្ដាប់ ហើយដូច្នេះមេធាវីការពារក្ដីអាចតាំងសំណួរដល់លោក Heder ថាភស្តុតាងអ្វីខ្លះដែលគាត់អាចផ្ដល់ជំនួសឲ្យការតាំងសំណួរតើភស្តុតាងបន្ថែមអ្វីខ្លះគាត់អាចផ្ដល់នៅក្នុងការគាំទ្រដល់សម្រង់នោះ ។ បើទោះបីការជំទាស់នេះកាន់តែមិនពាក់ព័ន្ធច្រើនឡើងៗ និងមិនសមហេតុផលផងនោះ (វាហាក់ដូចជាមានសារៈសំខាន់កាន់តែច្រើនឡើងៗដើម្បីសួរដេញដោលលោក Heder ទាក់ទងនឹងការអះអាងលើអង្គហេតុនានាដែលគាត់មិនមានការគាំទ្រយ៉ាងជាក់ច្បាស់) សូម្បីនៅទីនេះអង្គជំនុំជម្រះមិនយកចិត្តទុកដាក់អ្វីទាំងអស់ចំពោះវិធានដែលកំពុងអនុវត្ត ដោយការកាត់ផ្ដាច់ microphone របស់មេធាវីការពារនៅចុងបញ្ចប់នៃការសួរដេញដោលសាក្សី គឺនៅចំពេលមេធាវីការពារពន្យល់ថាសម្រង់ដែលគាត់ទើបតែអាន រួមបញ្ចូលទាំងជើងអក្សរ១១ផងដែរ[7]។

៩. ភាពខុសគ្នារវាងរបៀបនៃការតាំងសំណួររបស់សហព្រះរាជអាជ្ញាមកលើលោក Heder និងរបៀបនៃការតាំងសំណួររបស់មេធាវីការពារក្ដី មិនមែនដោយការចៃដន្យទេ។ និយាយឲ្យចំទៅលោក Heder គឺជាសាក្សីដាក់បន្ទុកៈ គាត់បំរើការងារឲ្យទាំងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងស្ថាប័ន Academic ដទៃទៀត។ គាត់បានសិក្សាស្រាវជ្រាវដែលភាគច្រើនបំផុតទទួលខុសត្រូវដោយផ្ទាល់ដែលឈានទៅដល់ការសម្រេចចោទប្រកាន់មកលើ នួន ជា ។ អង្គជំនុំជម្រះមិនគួរភ្ញាក់ផ្អើលទេដែលថា សហព្រះរាជអាជ្ញាចង់តែតាំងសំណួរចំពោះ

---

[6] ប្រតិចារិតថ្ងៃទី១៦ ខែកក្កដា នៅទំព័រ 76:15-23, 124:14-125:5

[7] ប្រតិចារិតថ្ងៃទី១៦ ខែកក្កដា នៅទំព័រ 127: 21

លោក Heder ដើម្បីបន្ថែមការគាំទ្រលើភស្តុតាងដាក់បន្ទុកដែលគាត់បានផ្តល់នាពេលកន្លងមក ហើយដែលជាភស្តុតាងរួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះ។ ពិតណាស់គោលបំណងរបស់មេធាវីការពារក្តី គឺខុសគ្នា: គឺជំទាស់ទៅនឹងមូលដ្ឋាននៃការដឹងរបស់លោក Heder ។ ការដែលអង្គជំនុំជម្រះអនុញ្ញាតឱ្យសហព្រះរាជអាជ្ញារឹតត្បិតការសួរដេញដោលរបស់មេធាវីការពារក្តី គឺពិតជាមិនសមស្របជាមួយកិច្ចខិតប្រឹងប្រែងនោះទេ។ មេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យតាំងសំណួរមកលើសាក្សីដាក់បន្ទុកថា តើគាត់បានបន្ថែមការគាំទ្រចំពោះការថ្លែងរបស់គាត់នៅក្នុងកំណត់ត្រាដែរ ឬយ៉ាងណា ។ ពុំមានការតាំងសំណួរជាសំខាន់ទាក់ទងនឹងអង្គហេតុ ហើយក៏ពុំមានការសួរដេញដោលដែលកើតចេញពីដំណើរការនិតីវិធីនោះទេ។

១០. ទីពីអង្គជំនុំជម្រះបានរារាំងមេធាវីការពារក្តីពីការតាំងសំណួរដែលសំខាន់ និងពាក់ព័ន្ធនឹងភស្តុតាងដែលលោក Heder បានប្រមូលអត្ថបទច្រើនសន្ធឹកសន្ធាប់ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ដែលជាចំណុចស្នូលនៃការសួរដេញដោលលោក Heder ដូចដែលអង្គជំនុំជម្រះបានពិពណ៌នានៅមុខការបង្ហាញខ្លួនរបស់គាត់ ។ ឧទាហរណ៍សំណួរជាច្រើនទាក់ទងនឹងភាពអាចជឿទុកចិត្តបាននៃការសម្ភាសន៍ដែលបានធ្វើកន្លងមក និងឯកសារភស្តុតាង មានជាអាទិ៍ចម្លើយសារភាពដែលគាត់បានពិនិត្យ[8]។ សហព្រះរាជអាជ្ញាខ្លួនឯង បានសួរលោក Heder យ៉ាងយូរអំពីវិធីសាស្ត្ររបស់គាត់ [...][9] ។ ពិបាកពន្យល់អង្គជំនុំជម្រះយល់ឃើញថាសំណួរណាមួយអំពីប្រព្រឹត្តកម្មរបស់លោក Heder មកលើភស្តុតាង មិនអនុញ្ញាតទេដោយសារតែវាពាក់ព័ន្ធជាមួយ "វិធីសាស្ត្ររបស់គាត់" ហើយដូច្នេះ បង្កើតបានជាការវាយតម្លៃនៃ "គុណភាពនៃកិច្ចការរបស់អ្នកជំនាញ"[10]។

---

[8] ប្រតិចារិតថ្ងៃទី១៦ នៅទំព័រ 58: 1-15, 68: 19-22

[9] ប្រតិចារិតថ្ងៃទី១៦ នៅទំព័រ 51: 20-21

[10] ប្រតិចារិតថ្ងៃទី១៦ នៅទំព័រ 67:16-68:4, 72:17-25. ការជំទាស់របស់សហព្រះរាជអាជ្ញា គឺផ្អែកលើទស្សនៈខុសគ្នាបន្តិច- គឺថាក្នុងការតាំងសំណួរ មកលើលោក Heder សហព្រះរាជអាជ្ញាបានយោងចំពោះចម្លើយសារភាព និងបានពិភាក្សាសម្ភារៈដែលទទួលយកជាភស្តុតាង ។ សូមមើលផងដែរនៅទំព័រ 68:25-69:17 ដោយមិនគិតដល់ការតាំងសំណួររបស់សហព្រះរាជអាជ្ញា អត្ថបទសរសេរជាច្រើនរបស់លោក Heder ដែលផ្អែកលើសម្ភារៈចម្លើយសារភាព គឺជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ របៀបដែលលោក Heder ប្រើប្រាស់សម្ភារៈចម្លើយសារភាព គឺពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងការវាយតម្លៃ របស់អង្គជំនុំជម្រះនៃតម្លៃជាភស្តុតាងរបស់អត្ថបទសរសេរទាំងនេះ។ ក្នុងអំឡុងពេលផ្តល់សក្ខីកម្មបើសិន

១១. ដោយការគោរព ការសម្រេចនោះពុំមានទំនាក់ទំនងសមហេតុផលជាមួយការណែនាំរបស់អង្គជំនុំជម្រះទាក់ទងនឹងការដាក់កំហិតចំពោះការសួរដេញដោលលោក Heder ឬលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធណាមួយសម្រាប់ការសម្រេចពីការទទួលយកសំណួរក្នុងអំឡុងពេលផ្តល់សក្ខីកម្ម។ អ្វីគ្រប់យ៉ាងដែលលោក Heder បានធ្វើនាពេលកន្លងមក រួមទាំងការសម្ភាសន៍របស់គាត់ ឯកសារដែលគាត់បានអាន និងអង្គហេតុដែលគាត់បានប្រមូល គឺកើតចេញពីសមត្ថភាពរបស់គាត់ជាអ្នកជំនាញ។ នោះគឺជាចរិតលក្ខណៈនៃការងាររបស់គាត់ គាត់គឺជាអ្នកជំនាញ academic ។ តាមរយៈសនិទានរបស់អង្គជំនុំជម្រះ គ្រប់សំណួរលើប្រធានបទដែលលោក Heder អាចផ្តល់សក្ខីកម្មដ៏មានប្រយោជន៍ មិនត្រូវបានអនុញ្ញាតដោយសារវាពាក់ព័ន្ធនឹងការវាយតម្លៃការងាររបស់គាត់ជាអ្នកជំនាញ។ សម្រាប់មូលហេតុនោះ ក្នុងការសម្រេចពីភាពអាចទទួលយកបាននៃសំណួរដែលអង្គជំនុំជម្រះគួរតែបានសួរ គឺមិនមែនថា តើសំណួរទាំងនោះនៅក្នុងន័យអរូបី គឺពាក់ព័ន្ធជាមួយការងាររបស់លោក Heder ជាអ្នកជំនាញ ប៉ុន្តែថា តើពួកគេបាន*ស្វែងរកមតិអ្នកជំនាញដែរ ឬយ៉ាងណា*។ ជំនាញរបស់លោក Heder គឺមិនមែនវាយតម្លៃអថាភាពនៃឯកសារ និងអ្នកដែលគាត់បានសម្ភាសន៍ទេ តែនៅក្នុងនយោបាយ និងប្រវត្តិសាស្ត្ររបស់កម្ពុជា។ បើតាមនិយមន័យ សំណួរដែលស្វែងរកការបំភ្លឺពាក់ព័ន្ធនឹងប្រព្រឹត្តកម្មរបស់គាត់មកលើភស្តុតាងបឋម មិនអាចស្វែងរកសក្ខីកម្មពីអ្នកជំនាញបានទេ ដោយសារវាមិនមែនជាប្រធានបទដែលគាត់ជាអ្នកជំនាញ ។ម្យ៉ាងទៀតសំណួររបស់មេធាវីការពារក្តីមិនបានស្វែងរកឲ្យមតិពីលោក Heder ទេ ឧទាហរណ៍ថាតើចម្លើយសារភាពអាចអានដោយរបៀបណា ប៉ុន្តែសំណើសាមញ្ញអំពីថា *តើគាត់អានចម្លើយសារភាពរបៀបណា*។ នោះគឺជាសំណួរនៃអង្គហេតុ ហើយមិនមែនជាមតិទេ ដែលមិនគួរត្រូវបានជំទាស់យ៉ាងធ្ងន់ធ្ងរសោះ។ ហេតុដូច្នេះ សំណួរនេះធ្លាក់ក្នុងដែនកំណត់នៃការសួរដេញដោលលោក Heder ដោយសារអង្គជំនុំជម្រះបានកំណត់នៅក្នុងអនុស្សរណៈរបស់ខ្លួន ។ ការដែលថាសំណួរមួយមិនពាក់ព័ន្ធការពិត ឬមិនបានបន្តការចោទប្រកាន់ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ ក៏មិនមានន័យ

---

លោក Heder អាចឆ្លើយទៅនឹងសំណួរនៃអង្គហេតុអំពីរបៀបដែលគាត់ប្រើប្រាស់សម្ភារៈចម្លើយសារភាព ដែលពាក់ព័ន្ធនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះនៃមតិអ្នកជំនាញរបស់គាត់ នោះសំណួរទាំងនោះនឹងត្រូវបានស្តាប់ជាពុំខានឡើយ ។

ថាវាមិនបានស្វែងរកឲ្យបំភ្លឺអង្គហេតុដែលពាក់ព័ន្ធដែរ។ សំណួរអង្គហេតុដែលពាក់ព័ន្ធនឹងគុណភាព ភាពអាចជឿជាក់បាន និងតម្លៃភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ គឺជាចំណុចស្នូលចំពោះការសួរដេញដោល និងមានប្រយោជន៍យ៉ាងខ្លាំងដល់ការបង្កើតការពិត។

១២. ការពិភាក្សានេះ ត្រូវបានហាមឃាត់ទាំងស្រុងដោយអង្គជំនុំជម្រះលើការតាំងសំណួរដែលទាក់ទងនឹងការអះអាងរបស់លោក Heder ទាក់ទងនឹងការងាររបស់លោក Kiernan ។ មេធាវីការពារក្តីបានតាំងសំណួរលោក Heder ដោយការអានសម្រង់ពីអត្ថបទមួយរបស់លោក Heder និងបានសួរគាត់ថាតើគាត់មានព័ត៌មានដែលអាចបញ្ជាក់ពីការអះអាងនៅក្នុងកិច្ចការរបស់គាត់នៅក្នុងសំណុំរឿង[11]។ សម្រង់ពីអត្ថបទនិពន្ធរបស់លោក Heder ដែលពាក់ព័ន្ធចំពោះការអះអាងរបស់លោក Kiernan ទាក់ទងនឹងរចនាសម្ព័ន្ធ និងមេដឹកនាំនៅភូមិភាគបូព៌ា អាចផ្អែកលើព័ត៌មានអង្គហេតុដែលលោក Heder បានដឹង។ មេធាវីការពារក្តីបានតាំងសំណួររបស់ខ្លួនដូចវិធីសាស្ត្រតាំងសំណួរដោយសហព្រះរាជអាជ្ញាដែរ ដោយបានសួរសាក្សីដោយមិនបាននិយាយស្មានៗ និងផ្តល់គំនិត ថាតើគាត់មានព័ត៌មានអង្គហេតុដើម្បីគាំទ្រសម្រង់ដែលបានអាននេះដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យតាំងសំណួរទាំងនេះទេ ដោយសារអត្ថបទដែលមេធាវីសំអាង "ត្រូវបានគេសន្មត់ថានិពន្ធដោយលោក Heder ក្នុងសមត្ថភាពជាអ្នកជំនាញ"[12]។ ជាថ្មីម្តងទៀតការសម្រេចនេះខកខានមិនបានសួរសំណួរពាក់ព័ន្ធទេ: ថាតើមេធាវីការពារកំពុងតែស្វែងរកការលាតត្រដាង ព័ត៌មានអង្គហេតុ ឬភស្តុតាងជំនាញ។

១៣. ទីបីផ្ទុយនឹងយុត្តិសាស្ត្រដ៏លេចធ្លោរបស់ខ្លួន អង្គជំនុំជម្រះដាក់ការហាមឃាត់យ៉ាងតឹងរឹងមិនឲ្យតាំងសំណួរណាមួយដែលទាក់ទងនឹងសកម្មភាពណាមួយ ដែលកើតឡើងក្នុងអំឡុងពេលស៊ើបសួរ។ ផ្ទុយពីការកំណត់យុត្តិសាស្ត្រនោះរបស់សហព្រះរាជអាជ្ញានៅក្នុងការជំទាស់របស់គេទៅនឹងការតាំងសំណួររបស់មេធាវីការពារក្តី[13] នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២

[11] ប្រតិចារិកថ្ងៃទី១៦ នៅទំព័រ 75:18-76:1

[12] ប្រតិចារិកថ្ងៃទី១៦ នៅទំព័រ 77:6-10, 81:12-19

[13] ប្រតិចារិកថ្ងៃទី១៦ នៅទំព័រ 24:25-25:5

អង្គជំនុំជម្រះយល់ឃើញថា នៅក្រោមកាលៈទេសៈមួយចំនួនអង្គជំនុំជម្រះនឹងស្តាប់ "សេចក្តីសន្និដ្ឋានជាក់លាក់ និងមានមូលហេតុ"ទាក់ទងនឹងវិធីសាស្ត្រនៃការប្រមូលភស្តុតាងដែលបានប្រើក្នុងពេលស៊ើបសួរ[14]។ សហព្រះរាជអាជ្ញាខកខានមិនបានផ្តល់មូលហេតុដើម្បីគាំទ្រដល់ការជំទាស់របស់គេ ក្រៅតែពីការរារាំងមិនឲ្យតាំងសំណួរទៅសាក្សីអំពីព្រឹត្តនានាក្នុងអំឡុងពេលស៊ើបសួរឡើយ[15]។ ម្យ៉ាងទៀតអង្គជំនុំជម្រះក៏មិនបានផ្តល់មូលហេតុណាមួយដើម្បីគាំទ្រដល់ការជំទាស់នេះដែរ[16]។ ការធ្វើដូច្នេះអង្គជំនុំជម្រះត្រឡប់មកអនុវត្តវិធានតឹងរឹង ដែលខ្លួនធ្លាប់ប្រើម្តងម្កាលក្នុងកំឡុងឆ្នាំ២០១២ ដែលបានហាមឃាត់ភាគីមិនឲ្យសួរសាក្សីលើប្រធានបទដែលទាក់ទងនឹងការស៊ើបសួរ បើទោះបីការសួរនោះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសារធាតុរបស់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនេះ[17]។

១៤. ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅពេលនោះ វិធានដែលអនុវត្តចំពោះ "កំហុសនិតិវិធី មិនអាចមោឃភាពដើម្បីរារាំងភាគីមិនឲ្យលើកសំណួរអង្គហេតុដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងតម្លៃភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនេះឡើយ[18]។ លោក Heder គឺជាសាក្សីពិសេសដែលធ្លាប់ទទួលខុសត្រូវពង្រាងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ហើយបន្ទាប់មកក៏បានស៊ើបសួរបទចោទនានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរជំនួសឲ្យសហចៅក្រមស៊ើបអង្កេត។ គាត់បានឃើញដោយផ្ទាល់

---

[14] ឯកសារ E-251 "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងភាពមិនប្រក្រតីដែលត្រូវបានគេចោទបានកើតឡើងក្នុងអំឡុងពេលស៊ើបសួរ (E221, E223, E224, E224/2, E234, E234/2, E241, E241/1) ។

[15] ប្រតិចារិកថ្ងៃទី១៦ ខែកក្កដា នៅទំព័រ 24:23-25:12, 27:10, 27:24-25

[16] ប្រតិចារិកថ្ងៃទី១៦ ខែកក្កដា នៅទំព័រ 26:2-8, 26:18-23, 27:12-15

[17] សូមមើលឯកសារ E-234 "សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការបំភ្លឺពីការិយាល័យសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការសួរដេញដោលសាក្សី នង សុផល នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតឲ្យផ្តល់ភស្តុតាងទាក់ទងនឹងការស្តាប់ចម្លើយសាក្សីនេះ" ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២("សំណើ អៀង សារី") នៅកថាខណ្ឌ២ ។ ឯកសារ E-234/2 "ការជូនដំណឹងនៃសំណើររួម E-234 របស់ អៀង សារី" ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១២ ("នួន ជា ចូលរួមសំណើ អៀង សារី") នៅកថាខណ្ឌ៣,៥ ។

[18] សំណើ អៀង សារី") នៅកថាខណ្ឌ៥-៧ ។ សំណើរបស់ នួន ជា ចូលរួមជាមួយសំណើ អៀង សារី នៅកថាខណ្ឌ១១-១២។

ផ្អែកនូវព្រឹត្តិការណ៍នានា ដែលចៅក្រម Lemonde ត្រូវបានគេចោទប្រកាន់ថាណែនាំបុគ្គលិករបស់គាត់ឱ្យស៊ើបរកតែភស្តុតាងដាក់បន្ទុក។ តុលាការអាចខកខានមិនបានស្វែងរកភាពពាក់ព័ន្ធរបស់អង្គហេតុទាំងនេះសម្រាប់តម្លៃភវនីយភាព នៃភស្តុតាងនៅចំពោះមុខខ្លួន។ តុលាការអាចមិនចាប់អារម្មណ៍នៅក្នុងការស្វែងយល់ឱ្យបានច្រើនអំពីតួនាទីរបស់លោក Heder នៅក្នុងការស៊ើបសួរ និងកម្រិតនៃឥទ្ធិពលរបស់គាត់លើការសម្រេចនានាដោយការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យចៅក្រមស៊ើបអង្កេត។

១៥. ក្ដីបារម្ភមានកាន់តែខ្លាំងឡើងនៅក្នុងការវិវត្តន៍នានានៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងទួលពោធិ៍ជ្រៃ- ទីកន្លែងបទល្មើសតែមួយគត់ដែលត្រូវបានពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះនេះមេធាវីការពារក្ដីបានលើកឡើងដោយមានមូលហេតុនៅក្នុងការដាក់ឯកសារថ្មីៗនេះ- ដែលមិនត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញា -ថាការស្ដាប់សក្ខីកម្មសាក្សី អ៊ុង ឆាត និង លឹម សាត សហចៅក្រមស៊ើបអង្កេតមិនបានពិនិត្យភស្តុតាងឱ្យបានដិតដល់ទាក់ទងនឹងការចោទប្រកាន់នៅទួលពោជ្រៃ ហើយជំនួសមកវិញទទួលយកជាភស្តុតាងដាក់បន្ទុក[19]។ ទម្រង់នៃដំណើរការនិតីវិធីនេះដូចគ្នាពិតៗទៅនឹងការលំបាកនៃការស្ដាប់សក្ខីកម្មរបស់លោក Heder ដោយអង្គជំនុំជម្រះ ដោយការសួរគាត់ឱ្យបញ្ជាក់ពីការពិតនៃការថ្លែងរបស់គាត់ដែលធ្វើនាពេលកន្លងមក ជំនួសឱ្យការសួរបន្ថែមពីលទ្ធភាពដែលមូលដ្ឋាននៃកំណត់ហេតុទាំងនោះអាចមិនត្រូវបានជឿជាក់។

១៦. មេធាវីការពារកត់សំគាល់ថា ការសម្រេចជាច្រើនដែលចេញនៅដំណាក់កាលស៊ើបអង្កេតទាក់ទងនឹងតួនាទីរបស់លោក Heder នៅការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យចៅក្រមស៊ើបអង្កេត ឬការណែនាំរបស់ចៅក្រម Lemonde ឱ្យស្វែងរកតែភស្តុតាងដាក់បន្ទុក មានភាពលំអៀង-អាចជាមូលដ្ឋានសម្រាប់ការដិតចិត្តអនុលោមតាមវិធាន ៣៤[20] ឬធ្វើជាគន្លឹះដើម្បីមោឃភាពអនុលោមតាមវិធាន ៧៦(២)[21]។ នៅក្នុងករណីទាំងពីរ

---

[19] ឯកសារ E-291 "សំណើជាបន្ទាន់សុំកោះហៅសាក្សីសំខាន់ទាក់ទងនឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ២៦-២៧។

[20] សូមមើលសំណុំរឿង 00២/0៩-១0-២00៩/អវតក/អបជ(0១) ឯកសារលេខ៧ "សេចក្ដីសម្រេចលើបណ្ដឹងដិតចិត្តរបស់អៀង សារី ប្រឆាំងនឹងចៅក្រម Lemonde ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២00៩" ។ សំណុំរឿង00២/១៣-១0-២00៩/អវតក/អបជ

អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ មិនត្រូវបានរំលោភ ហើយថាបទដ្ឋានច្បាប់សម្រាប់ការបង្ហាញនូវការលម្អៀង មិនត្រូវបានបង្កើតឡើយ-នៅក្នុងករណីលោក Heder ពីព្រោះសច្ចធារណ៍នៃភាពលម្អៀង មិនត្រូវបានអនុវត្តសម្រាប់ករណីបុគ្គលិក និងចៅក្រម Lemonde [22]។ នៅក្នុងករណីណាក៏ដោយប្រសិនបើមានការពិចារណាលើបញ្ហាដែលធ្វើឱ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ នោះគឺភាពជឿជាក់បាននៃភស្តុតាង។

១៧. នៅក្នុងទស្សនទានទាំងបីនេះ សហព្រះរាជអាជ្ញា ព្រមទាំងអង្គជំនុំជម្រះបានជ្រៀតជ្រែកដោយជោគជ័យការស្វែងរកអង្គហេតុដែលលោក Heder បានដឹង និងការសួរដេញដោលដោយមានសារៈសំខាន់។ សក្ខីកម្មរបស់គាត់មិនមែនជាការខិតខំប្រឹងប្រែងដើម្បីបង្កើតការពិតទេ តែជាលេសមួយដើម្បីគាំទ្រដល់ទទួលយកកិច្ចការរបស់គាត់ដែលមាននៅក្នុងសំណុំរឿង[23]។

(០២) ឯកសារលេខ៧ "សេចក្តីសម្រេចលើ បណ្តឹងជំទាស់របស់ ខៀវ សំផន ប្រឆាំងនឹងចៅក្រម Lemonde ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩"។ សំណុំរឿង០០២/០៨-០៧-២០០៩/អវតក/អបជ(០២) ឯកសារលេខ៣ "សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ ជនជាប់ចោទប្រឆាំងនឹង Dr Stephen Heder និង David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩"។

[21] សូមមើលឯកសារ D-263/2/6 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធិរិទ្ធ ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត បដិសេធចោលសំណើរសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើដែលឈានទៅរកការមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ។ ឯកសារ D402/1/4 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់ អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលធ្វើឡើងដោយ ឬគាំទ្រដោយ Dr Stephen Heder និង David Boyle និងសំណើរបស់ អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះទទួលយកសំណើសុំមោឃភាពភស្តុតាងទាំងអស់ដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬបណ្តឹងឧទ្ធរណ៍ជាបន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ សហចៅក្រមស៊ើបអង្កេតមិនបង្អង់ដំណើរការនិតីវិធី" ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១០ នៅកថាខណ្ឌ២៨-៣៦ ។

[22] សូមមើលជើងអក្សរលេខ២០-២១ ខាងលើ ។

[23] ការគាំទ្រដល់ការជំទាស់ អង្គជំនុំជម្រះបានព្រមានច្រំដែលៗមកលើមេធាវីការពារក្តីអំពីការទទូចរបស់ខ្លួននៅក្នុងអំឡុងពេលការសួរដេញដោលដោយសហព្រះរាជអាជ្ញាថា លោក Heder ត្រូវបានចាត់ទុកថាជាសាក្សី មិនមែនអ្នកជំនាញទេ។ វាពិតជាដូច្នេះមែន។ មេធាវីការពារបានជំទាស់សំណួររបស់សហព្រះរាជអាជ្ញាប្រាំមួយដង។ ពិតណាស់ភាពខុសគ្នាគឺថាការជំទាស់តែមួយគត់ក្នុងចំណោមការជំទាស់ទាំងអស់ (ក៏ពុំមានការជំទាស់ណាមួយលើកឡើងដោយក្រុមមេធាវី ខៀវ

## II. ការសម្រេចរបស់ នួន ជា មិនផ្តល់សក្ខីកម្ម

១៨. នួន ជា ស្វែងរកការបញ្ជាក់ដល់អង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន ថាការសម្រេចចិត្តរបស់គាត់មិនផ្តល់សក្ខីកម្ម គឺជារឿងថ្មី។ ការសម្រេចនេះមិនបាន ព្រៀងទុកជាមុនទេ។ វាជាការសម្រេចចិត្តដែលគាត់សោកស្តាយ។ វាជាការសម្រេចដែល គាត់ត្រូវតែធ្វើ ដោយសារគាត់ដឹងយ៉ាងច្បាស់ថាអង្គជំនុំជម្រះនេះនឹងមិនវាយតម្លៃឲ្យបាន ល្អិតល្អន់នូវភស្តុតាងនៅចំពោះមុខខ្លួន។ វាហាក់ដូចជាថា អង្គជំនុំជម្រះមិនបានស្វែងរក ការស្តាប់សក្ខីកម្មរបស់គាត់ ដើម្បីដឹងឲ្យបានពេញលេញអំពីបក្សកុម្មុយនីស្តកម្ពុជា ឬមូល ហេតុ និងយុត្តិកម្មនៃការអំពើរបស់គាត់។ ជំនួសមកវិញ អង្គជំនុំជម្រះកំពុងទាញយកសក្ខី កម្មរបស់គាត់សម្រាប់ប្រើនៅក្នុងការដាក់ទោសប៉ុណ្ណោះ។ នួន ជា មិនអាច និងមិនចូល រួមក្នុងដំណើរការបែបនេះទេ។

**សហមេធាវីការពារក្តីលោក នួន ជា**




**សុន អរុណ** Victor KOPPE

---

សំផន) ត្រូវបានគាំទ្រ។ សូមមើលឯកសារ E-1/221.1 “ប្រតិចារិតសវនាការ” ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ នៅទំព័រ 58:5-19, 89:1-90:6, 106:11-25។ ឯកសារ E-1/222.1 “ប្រតិចារិតសវនាការ” ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ នៅទំព័រ 51:11-52:25 ។ តែផ្ទុយទៅវិញសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យបន្តដោយលើកឡើងថា សំណួរនិមួយៗជាអារម្ភកថា ដោយ បង្គាប់ទៅសាក្សី ត្រូវកម្រិតការឆ្លើយតបត្រឹមវិសាលនៃចំណេះដឹងផ្ទាល់ខ្លួន។ អង្គជំនុំជម្រះមិនខ្វល់នឹងការលើកឡើង នូវវិធីដូចគ្នានេះដោយមេធាវីការពារក្តី។